
www.kidsofdestiny.org
Kids of Destiny®
Reaching the Next Generation

Kids of Destiny®
Reaching the Next Generation

## 1.05 ទឹកជំនន់ដ៏ធំមហិមារ

**លោកុប្បត្តិ ៦: ១១-២២; ៧: ១១-២៣; ៨: ១៤-២២**

ជាច្រើនឆ្នាំកន្លងផុតទៅមនុស្សកាន់តែច្រើនឡើងៗ នៅលើផែនដី។ ទោះយ៉ាងណាក៏ដោយ ពួកគេភាគច្រើនបានជ្រើសរើសធ្វើរឿងមិនល្អ ហើយបន្តរស់នៅក្នុងអំពើបាប។ រឿងនេះបានធ្វើឱ្យព្រះអម្ចាស់ខូចព្រះទ័យជាខ្លាំង ទ្រង់មានអារម្មណ៍សោកស្តាយមែនទែនដែលទ្រង់បានបង្កើតមនុស្សមក។ នៅទីបំផុតព្រះទ្រង់បានសម្រេចចិត្តថាមានវិធីតែមួយគត់ ដើម្បីកម្ចាត់អំពើបាប និងអំពើអាក្រក់ពីក្នុងពិភពលោកគឺគ្របដណ្តប់ផែនដីទៅដោយទឹកជំនន់ដ៏ធំ។

ទោះយ៉ាងណាក៏ដោយ មានបុរសម្នាក់ដែលនៅតែជ្រើសរើសធ្វើល្អ ហើយឈរលើគោលការដែលត្រឹមត្រូវ។ គាត់ស្រឡាញ់ព្រះ ហើយដើរតាមទ្រង់ក្នុងគ្រប់ការទាំងអស់។ គាត់ឈ្មោះណូអេ។ ព្រះទ្រង់បានប្រាប់ណូអេអំពីផែនការបំផ្លាញលោកីយ៍ ប៉ុន្តែទ្រង់បានសន្យាថា នឹងរក្សាណូអេនិងក្រុមគ្រួសាររបស់គាត់ឲ្យមានសុវត្ថិភាព។ ដូច្នេះព្រះទ្រង់បានប្រាប់គាត់នូវវិធីយ៉ាងល្អិតល្អន់ អំពីរបៀបសាងសង់ទូកធំមួយដែលហៅថាទូកដ៏ធំ។ ព្រះទ្រង់បានឲ្យណូអេនូវខ្នាតរង្វាស់និងកន្លែងដែលត្រូវដាក់ទ្វារនិងរបៀបសង់ដំបូល។ ដោយសារណូអេជឿលើព្រះ គាត់បានធ្វើតាមការណែនាំទាំងប៉ុន្មាន ដែលព្រះទ្រង់បានប្រទានដល់គាត់ ។

នៅពេលដែលគាត់ និងក្រុមគ្រួសារកំពុងមមាញឹកសាងសង់ទូកធំ មនុស្សជាច្រើននៅជុំវិញគាត់សើចចំអកដាក់គាត់ ហើយគិតថាពួកគេឆ្កួត។ យ៉ាងណាក៏ដោយណូអេនៅតែរក្សាជំនឿរបស់គាត់ ហើយបន្តការងារសាងសង់ទូកធំ ដូចដែលព្រះទ្រង់បានណែនាំឲ្យគាត់ធ្វើ។ នៅពេលដែលអ្វីៗបានត្រៀមរួចរាល់ហើយ ព្រះបានប្រាប់ណូអេ ឲ្យនាំប្រពន្ធនិងកូនប្រុសទាំងបីរបស់គាត់ និងប្រពន្ធរបស់ពួកគេ ចូលក្នុងទូកធំនោះ។ ព្រះបានឲ្យសត្វមានជីវិតមួយគូរៗ គឺញីមួយ និងឈ្មោលមួយ ចូលទៅក្នុងទូកធំផងដែរ។ នៅពេលពួកគេចូលក្នុងទូកអស់ហើយ ព្រះទ្រង់ក៏បានបិទទ្វារ។ បន្ទាប់មកព្រះទ្រង់បានបង្អុរទឹកភ្លៀង ហើយមេឃក៏ភ្លៀងអស់រយៈពេលសែសិបថ្ងៃសែសិបយប់។ ទឹកបានកើនឡើង និងគ្របដណ្តប់លើផែនដីទាំងមូលសូម្បីតែភ្នំខ្ពស់បំផុត។ គ្មានភាវៈរស់ណាមានជីវិតឡើយ លើកលែងតែអ្នកដែលនៅក្នុងទូក។ អស់រយៈពេល ១៥០ ថ្ងៃទឹកបានគ្របដណ្តប់លើផែនដីទាំងស្រុង។

កន្លងទៅ១៥០ថ្ងៃទៀត ទីបំផុតទូកធំបានកឿនលើភ្នំធំមួយ។ បន្ទាប់ពីរង់ចាំជាច្រើនថ្ងៃបន្តទៀត ណូអេបានបើកបង្អួចហើយព្រលែងសត្វក្អែកមួយក្បាល។ សត្វក្អែកបានហើរទៅវិញ ទៅមករហូតទាល់តែទឹករីង។ បន្ទាប់មក ណូអេបានព្រលែងសត្វព្រាប ប៉ុន្តែវាបានត្រឡប់មកទូកវិញព្រោះ មិនអាចរកកន្លែងទុំបានទេ។ មួយសប្តាហ៍ក្រោយមកណូអេបានព្រលែងសត្វព្រាបម្តងទៀត។ លើកនេះវាបានត្រលប់មកវិញដោយពាំស្លឹកអូលីវមកជាមួយ។ ពេលនេះណូអេបានដឹងថាដីចាប់ផ្តើមប្រែជាពណ៌បៃតងហើយ។ សប្តាហ៍បន្ទាប់ណូអេបានព្រលែងសត្វព្រាបម្តងទៀត ហើយលើកនេះវាមិនបានវិលត្រឡប់មកវិញទេ។ ដីបានស្ងួតហើយ។

នៅទីបំផុតណូអេនិងក្រុមគ្រួសាររបស់គាត់ព្រមទាំងសត្វទាំងអស់ក៏បានចេញពីទូកធំ។ ណូអេមានចិត្តអរព្រះគុណដល់ទ្រង់ដែលបានរួចជីវិត ហើយគាត់ក៏បានថ្វាយបង្គំព្រះអម្ចាស់។ ព្រះទ្រង់បានសន្យាថាទ្រង់ នឹងមិនពន្លិចផែនដីដោយសារទឹកជំនន់ទៀតឡើយ។ ព្រះបានដាក់ឥន្ទធនូមួយនៅលើមេឃជាសញ្ញានៃការសន្យារបស់ទ្រង់ ។

**ទំនុកតម្កើង ៧:១០** ខែលនៃទូលបង្គំនៅជាមួយនឹងព្រះ ដែលទ្រង់ជួយសង្គ្រោះមនុស្សមានចិត្តទៀងត្រង់

## 1.05 ទឹកជំនន់ដ៏ធំមហិមា - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

### កំណត់សំគាល់:

១. មនុស្សកាន់តែមានចំនួនច្រើនឡើងៗ គេនៅតែបន្តមិនស្តាប់បង្គាប់ព្រះ និងជ្រើសធ្វើរឿងមិនល្អជាច្រើន។ ព្រះទ្រង់បានសម្រេចចិត្តថា ត្រូវតែកម្ចាត់អំពើបាប និងអំពើអាក្រក់នេះចេញ។ ទ្រង់សម្រេចថា នឹងពន្លិចផែនដីដោយសារទឹកជំនន់។

២. ពេលនោះមានបុរសម្នាក់នៅតែបន្តស្តាប់បង្គាប់ព្រះ។ គាត់ឈ្មោះថាណូអេ។ ព្រះទ្រង់មានព្រះបន្ទូលប្រាប់ណូអេអំពីគម្រោពន្លិចផែនដីរបស់ទ្រង់។ ទ្រង់បង្គាប់ឲ្យណូអេសាងសង់ទូកដ៏ធំមួយ។ ទូកធំអាចដាក់មនុស្ស និងអ្វីផ្សេងៗទៀតដែលព្រះទ្រង់ចង់ជួយសង្គ្រោះ ។

៣. ពេលទឹកជំនន់ជិតមកដល់ ព្រះទ្រង់ឲ្យណូអេនាំគ្រួសារគាត់ទាំងមូលចូលទូកធំ ប្រពន្ធគាត់ កូនប្រុសទាំងបីរបស់គាត់និងប្រពន្ធរបស់កូនៗគាត់។ ព្រះទ្រង់ឲ្យណូអេនាំសត្វមួយគូៗញីមួយឈ្មោលមួយផងដែរ។ ពេលដែលគេចូលទូកអស់ហើយ ភ្លៀងក៏ចាប់ផ្តើមបង្អុរចុះមក។

៤. ទឹកបានជន់ជោរលើផែនដីរយៈពេល១៥០ថ្ងៃ។ ក្រោយមកទូកក៏កឿងលើភ្នំធំមួយ ណូអេបានប្រលែងក្អែកមួយទៅ ក្រោយមកក៏ប្រលែងសត្វព្រាបមួយទៀត។ គាត់សង្ឃឹមថានឹងរកឃើញដីគោក មានតែសត្វព្រាបទេដែលមកវិញ។ យូរបន្តិចក្រោយមក ណូអេប្រលែងសត្វព្រាបម្តងទៀត សត្វព្រាបពាំមកវិញនូវស្លឹកអូលីវ វាមានន័យថា មានដីគោកវិញហើយទឹកក៏ស្រកដែរ។

៥. ណូអេ និងក្រុមគ្រួសារមានចិត្តអរព្រះគុណព្រះមែនទែន ដែលទឹកជំនន់បានចប់ គេសរសើរតម្កើងដល់ព្រះ។ ព្រះទ្រង់បានដាក់ឥន្ធនូនៅលើមេឃ ជាសញ្ញានៃសេចក្តីសន្យាថា នឹងទ្រង់មិនពន្លិចផែនដីដោយសារទឹកជំនន់ទៀតឡើយ។

### សំណួរ

១) តើព្រះទ្រង់បានសម្រេចចិត្តធ្វើអ្វីនៅពេលដែលមានអំពើបាប និងអំពើអាក្រក់ច្រើននៅលើផែនដី?

២) តើនរណាដែលជាមនុស្សចុងក្រោយនៅតែទុកចិត្ត និងស្តាប់បង្គាប់ព្រះ?

៣) តើព្រះបង្គាប់ឲ្យណូអេធ្វើអ្វី?

៤) តើនរណាខ្លះបានចូលទៅក្នុងទូកធំ?

៥) តើសត្វអ្វីបានពាំស្លឹកអូលីវមកវិញ ដែលបញ្ជាក់ថាមានដីហើយ?

៦) តើព្រះបានដាក់អ្វីជាសញ្ញា បញ្ជាក់ថា ទ្រង់នឹងមិនពន្លិចផែនដីដោយសារទឹកជំនន់ទៀតឡើយ?

### ចម្លើយ

១) ព្រះទ្រង់សម្រេចព្រះទ័យថា នឹងពន្លិចផែនដីដោយទឹកជំនន់ ដើម្បីបំផ្លាញអំពើបាបនិងអំពើអាក្រក់។

២) ណូអេជាមនុស្សចុងក្រោយដែលនៅតែស្តាប់បង្គាប់និងទុកចិត្តព្រះ ។

៣) ព្រះទ្រង់បង្គាប់ឲ្យណូអេសាងសង់ទូកធំ។

៤) អ្នកដែលបានឡើងទូកគឺ ណូអេ ប្រពន្ធគាត់ កូនប្រុសទាំងបី ប្រពន្ធកូនគាត់និងសត្វមួយគូៗ ។

5) សត្វព្រាបបានពាំមកវិញនៅស្លឹកអូលីវ ដែលបញ្ជាក់ថាមានដីវិញហើយ។

៦) ព្រះទ្រង់បានដាក់ឥន្ធនូនៅលើមេឃដែលជាសញ្ញាបញ្ជាក់ថា ទ្រង់នឹងមិនពន្លិចផែនដីដោយសារទឹកជំនន់ទៀតឡើយ។

